# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២២២៥ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០០២

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតវិទ្យាស្ថានគ្រប់គ្រងបុរេប្រទាន
## នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
### អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ ន.ស.រ.ក.ត ១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២.នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញព្រះរាជក្រមលេខនស.រកម ១២០១/១៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០២
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក. ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

- បានឃើញសារាចរណែនាំលេខ ០០៣ សហវ.ម ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីវដ្តទេយ្យបុរេប្រទាន
- បានឃើញប្រកាសលេខ ១២៩ ប្រក.សហវ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៧ ស្តីពីការកំណត់ទឹកប្រាក់វដ្តទេយ្យបុរេប្រទានជំពូក ១១ សំរាប់ទូទាត់ចំណាយចាំបាច់ទៅលើដំណើរការរដ្ឋបាលសំភារៈ និង ការជួសជុលតូច
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

## សំរេច

ប្រការ១ : ត្រូវបានបង្កើតវដ្តទេយ្យបុរេប្រទានជំពូក ១១ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីទូទាត់ចំណាយទាំងឡាយណាដែលមានចែកក្នុងមាត្រា ៦៤ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ។ ចំនួនទឹកប្រាក់ជាអតិបរិមា នៃចំណាយដែលអនុញ្ញាតអោយវដ្តទេយ្យករបុរេប្រទានធ្វើការទូទាត់ត្រូវកំណត់កំរិតក្រោម ៥០០.០០០៛០០ ( ប្រាំរយពាន់រៀលគត់ ) តាមចំណាត់ថ្នាក់ចំណាយទីមួយ ១ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសអន្តរក្រសួង ។

ប្រការ២ : ចំនួនទឹកប្រាក់នៃវដ្តទេយ្យបុរេប្រទានជំពូក ១១ សំរាប់មួយជុំនៃឆ្នាំ ត្រូវបានកំណត់ត្រឹមចំនួន ២៤៤.៨២៥.០០០៛០០ ( ពីររយសែសិបបួនលានប្រាំបីរយម្ភៃប្រាំពាន់រៀលគត់ ) ។

ប្រការ៣ : សេចក្តីសំរេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៤ : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានភារៈកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
រដ្ឋលេខាធិការ
គង់ វិបុល

អគ្គលេខាធិការ
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
សុខ ចិន្តា

**កន្លែងទទួល**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៤
  " ដើម្បីមុខការ "
- ឯកសារ-កាលប្បវត្តិ